ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី១៩ លេខ៥៩

ត្រីមាសទី០៣ ឆ្នាំ២០១៩

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

៣០-០៧-២០១៩ -ព្រះរាជក្រម នស/រកម/០៧១៩/០១២ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអេសភីអេចភី (ខេមបូឌា) ឯ.ក ៦៧៩៣

២~ព្រះរាជក្រឹត្យ

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៨៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈិន ចៀនឆឺ** (CHEN, CHIEN-CHIH) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៦៨០៨

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៨៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **សៀល ចុងអ៊ី** (SHIEH, JON-YIE) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៦៨០៩

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៨៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្វូ សៀងភឹង** (FU, XIANGPENG) ជនជាតិចិន សញ្ជាតិចិន ៦៨១០

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៩០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោកស្រី **លីវ ថៃអ៊ី** (LIU, TAI-YU) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៦៨១១

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៩១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អ៊ី ហុងប៉ូ** (YU, HONGBO) ជនជាតិចិន សញ្ជាតិចិន ៦៨១២

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៩២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ាង ភឹង** (WANG, PENG) ជនជាតិចិន សញ្ជាតិចិន ៦៨១៣

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៩៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈិន វូស៊ីយ៉ុង** (CHEN WUXIONG) ជនជាតិចិន សញ្ជាតិចិន ៦៨១៤

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៩៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោកស្រី **ខូ ម៉ាន់ឈីង** (KHO MAN CHING) ជនជាតិចិន សញ្ជាតិចិន ៦៨១៥

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៩៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឌូ ស្វួយកាយ** (DOO SHUI KAY) ជនជាតិចិន សញ្ជាតិចិន ៦៨១៦

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៩៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វូ ឈីងមៀវ** (WU QINGMIAO) ជនជាតិចិន សញ្ជាតិចិន ៦៨១៧

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៩៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចាង លីន** (ZHANG, LIN) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ឈួន សម្បត្តិ** (CHUN SAMBATH) ៦៨១៨

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៩៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **តាន់ លូស៊ីហ្វើរ អាបេ** (TAN LUCIFER ABAY) ជនជាតិហ្វីលីពីន សញ្ជាតិហ្វីលីពីន ដោយប្តូរឈ្មោះជា **សាយ គីមអាង** (SAY KIM ANG) ៦៨១៩

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៩៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ័ង ហ្វូឌី** (HUANG, FUDI) ជនជាតិចិន សញ្ជាតិចិន ៦៨២០

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១១០០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ាង ហ្វូឈៀង** (WANG, FUQIANG) ជនជាតិចិន សញ្ជាតិចិន ៦៨២១

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១១០១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ូ ជីហ្វា** (SU, ZHIFA) ជនជាតិចិន សញ្ជាតិចិន ៦៨២២

II.រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨១៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៨២៣

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨១៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៨២៥

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨១៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៨៣១

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨១៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៨៣៣

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨១៨ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៦៨៣៧

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨១៩ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៦៨៣៩

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨២០ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មប្តូរប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៦៨៤១

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨២១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៨៤៣

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨២២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៨៤៤

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨២៣ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៦៨៤៥

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨២៤ អនក្រ.តត ស្តីពី ការលុបឈ្មោះ នាយទាហាន ៦៨៤៦

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨២៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៦៨៤៧

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨២៦ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៦៨៤៩

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨២៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៨៥០

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨២៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៨៥១

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨២៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៨៥៣

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨៣០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៨៥៤

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨៣១ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៦៨៥៥

២០-០៦-២០១៩ -អនុក្រឹត្យលេខ ៨៣២ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៦៨៥៦

២០-០៦-២០១៩ -អនុក្រឹត្យលេខ ៨៣៣ អនក្រ.តត ស្តីពី ការតែងតាំងទីប្រឹក្សាក្រសួងមហាផ្ទៃ ៦៨៥៧

២០-០៦-២០១៩ -អនុក្រឹត្យលេខ ៨៣៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៨៥៩

២០-០៦-២០១៩ -អនុក្រឹត្យលេខ ៨៣៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៨៦០

២០-០៦-២០១៩ -អនុក្រឹត្យលេខ ៨៣៦ អនក្រ.តត ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីនគរបាលជាតិកម្ពុជា ៦៨៦៣

២១-០៦-២០១៩ -អនុក្រឹត្យលេខ ៨៣៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៨៦៥

២១-០៦-២០១៩ -អនុក្រឹត្យលេខ ៨៣៨ អនក្រ.តត ស្តីពី ការតែងតាំងទីប្រឹក្សាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៦៨៦៦

២១-០៦-២០១៩ -អនុក្រឹត្យលេខ ៨៣៩ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែងមន្ត្រីរាជការ ៦៨៦៧

២១-០៦-២០១៩ -អនុក្រឹត្យលេខ ៨៤០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៨៦៨

III.ការងារបណ្ដាក្រសួង

១.ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៤-០៣-២០១៩ -ប្រកាសអន្តរក្រសួងលេខ ២៣៥ សហវ.ប្រក ស្ដីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ២០១៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៦៨៦៩

២២-០៣-២០១៩ -ប្រកាសលេខ ៣៣៨ សហវ.ប្រក ស្ដីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តឧត្តរមានជ័យ ៦៨៧៣

២២-០៣-២០១៩ -ប្រកាសលេខ ៣៣៩ សហវ.ប្រក ស្ដីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកោះកុង ៦៨៧៦

២២-០៣-២០១៩ -ប្រកាសលេខ ៣៤០ សហវ.ប្រក ស្ដីពី ការតែងតាំងរដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តសៀមរាប ៦៨៧៩

២២-០៣-២០១៩ -ប្រកាសលេខ ៣៤១ សហវ.ប្រក ស្ដីពី ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តសៀមរាប ៦៨៨១

២២-០៣-២០១៩ -ប្រកាសអន្តរក្រសួងលេខ ៣៤៤ សហវ.ប្រក ស្ដីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៩ របស់សាកលវិទ្យាល័យមានជ័យ នៃក្រសួងអប់រំ យុវជន និងកីឡា ៦៨៨៤

២៥-០៣-២០១៩ -ប្រកាសអន្តរក្រសួងលេខ ៣៥៥ សហវ.ប្រក ស្ដីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៩ របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា នៃក្រសួងអប់រំ យុវជន និងកីឡា ៦៨៨៩

២.ទីស្ដីការរដ្ឋមន្ត្រីក្រសួងការពារជាតិ និង ថាមពល

២៥-១២-២០១៨ -ប្រកាសលេខ ០៣១៨ រថ.អកទទ.ប្រក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានកិច្ចការទូទៅ ៦៨៩៤

ព្រះរាជក្រម

នស/រកម/០៧១៩/០១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុន អេសភីអេចភី (ខេមបូឌា) ឯ.ក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុន អេសគីអេចគី(ខេមបូឌា)ឯ.ក

មាត្រា១.–

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងរ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ឲ្យក្រុមហ៊ុន អេសគីអេចគី(ខេមបូឌា)ឯ.ក ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន អេសគីអេចគី(ខេមបូឌា)ឯ.ក និងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុន អេសគីអេចគី(ខេមបូឌា)ឯ.ក ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៩ ។ ការធានានេះ មានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៩ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ ។

មាត្រា២.–

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ ។

មាត្រា៣.–

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញ្ញាប់ ។

ថ្ងៃអង្គារ ១៤រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៩

នស.រកម.០៧១៩.០១៥

ន សីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៥ សរប្រក

ថ្ងៃព្រហស្បតិ៍ ៧កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៩

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- បានឃើញព្រះរាជក្រម លេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសម្បទាន
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- បានឃើញអនុក្រឹត្យ លេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការសម្រេច របស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩

រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង កិច្ចព្រមព្រៀងជួលដីទីតាំងគម្រោង ជាមួយក្រុមហ៊ុន អេសភីអេចភី (ខេមបូឌា) ឯ.ក និងលើលិខិតធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដោយអគ្គិសនីកម្ពុជា និង/ឬ ក្រសួងរ៉ែនិងថាមពល ទៅឱ្យក្រុមហ៊ុន អេសភីអេចភី (ខេមបូឌា) ឯ.ក សម្រាប់គម្រោងវារីអគ្គិសនីស៊ឹងពោធិ៍សាត់១ អានុភាព៨០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

ក្នុងករណីដែលឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ។

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាល
Royal Government

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

No 25 DFP

Phnom Penh, 11 April , 2019

DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0918/925 dated 06 of September 2018 on the nomination of the Royal Government of the Kingdom of Cambodia
- Seen the Royal Kram NS/RKM/0618/012 dated 28 of June 2018 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/0196/18 dated 24 of January 1996 promulgating the Law on the Establishment of the Ministry of Economy and Finance
- Seen the Royal Kram 03/NS/94 dated 05 0f August 1994 promulgating the Law on Investment of Kingdom of Cambodia and the Law on Amendment of Law on Investment of Kingdom of Cambodia promulgated by the Royal Kram NS/RKM/0303/009 dated 24 of March 2003
- Seen the Royal Kram NS/RKM/1007/027 dated 19 0f October 2007 promulgating the Law on Concessions
- Seen the Royal Kram NS/RKM/1218/017 dated 12 of December 2018 promulgating the Law on Finance for Management of the Year 2019
- Seen Sub-decree 111 អនក្រ.បក dated 27 of September 2005 on Implementation of the Law on Amendment of Law on Investment of Kingdom of Cambodia
- Referring to the decision of Council of Ministers in its plenary session on 5 April 2019

THE ROYAL GOVERNMENT

Delegates herewith to H.E. Dr. AUN PORNMONIROTH, Deputy Prime Minister, Minister of Economy and Finance, full power to sign the Implementation Agreement, Lease Agreement and the Governmental Guarantee of Payment by the EDC/MME to SPHP (Cambodia) Co., Ltd. for the Development of Stung Pursat 1 Hydroelectric BOT Project in Pursat Province.

These powers include the powers of delegation.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០១ សហវ.

ថ្ងៃ[illegible] ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១៩

លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូនចំពោះ ÷ **លោក MYUNG IL KIM**
ប្រធានក្រុមហ៊ុន អេសតិអេចតិ (ខេមបូឌា) ឯ.ក

អាសយដ្ឋាន ÷ លេខ ៩, ផ្លូវ LyLy, សង្កាត់និរោធ,
ខណ្ឌច្បារអំពៅ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរសារ ÷ (៨៥៥) ២៣ ៩៩៩ ១៣៣

យោង ÷

(ក) លិខិតសិទ្ធិប្រទាន លេខ ២៥ សប្រទ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** (លិខិតសិទ្ធិប្រទានក្នុងឧបសម្ព័ន្ធ១)។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩ ដែលបានចុះហត្ថលេខា រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល** (**រ.រ.ថ**) និងក្រុមហ៊ុន **អេសតិអេចតិ (ខេមបូឌា) ឯ.ក (ក្រុមហ៊ុន)**។

(គ) **អគ្គិសនីកម្ពុជា** ជាសហគ្រាសរដ្ឋ ទទួលខុសត្រូវមានកំណត់ ត្រូវបានបង្កើតឡើងដោយ ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (អ.ក), បានចុះកិច្ចព្រមព្រៀងទិញអគ្គិសនី (PPA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩។

(ឃ) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់ ÷ (១)-ការធានាលើការទូទាត់ថ្លៃទិញថាមពលអគ្គិសនី ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀង ស្របតាមកិច្ចព្រមព្រៀង PPA និង/ឬ IA និងក្នុងករណីដែលក្រុមហ៊ុន មិនអាចដំណើរការគម្រោងបាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ប្រធានសក្តិនយោបាយ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

(ង) តាមការតម្រូវក្នុងប្រការ ៥.៣ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.វ)** ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា **(អ្នកធានា)** បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាលើការទូទាត់ ដែលជាកាតព្វកិច្ចរបស់ អ.ក ឬ ក.រ.ថ ស្របតាម PPA និង IA។

ដូច្នេះ យើងខ្ញុំសូមធានា ថា÷

១. អ្នកធានាសូមធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុន នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ ក.រ.ថ ឬ អ.ក ឱ្យក្រុមហ៊ុន ក្រោមកិច្ចព្រមព្រៀង IA ឬ PPA ដែល ក.រ.ថ ឬ អ.ក ខកខានពុំបានទូទាត់ អនុលោមតាមអាណត្តិ នៃ IA ឬ PPA (លិខិតធានា)។

២. លិខិតធានានេះ ត្រូវជាការធានាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ ដែលត្រូវបង់ឱ្យក្រុមហ៊ុនគ្រប់ពេល ដោយ ក.រ.ថ ឬ អ.ក ក្រោមកិច្ចព្រមព្រៀង IA ឬ PPA ទោះជាមានលិខិតជូនដំណឹងណាមួយ ស្ដីពីការបញ្ចប់កិច្ចព្រមព្រៀង ឬការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្ដូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ក.រ.ថ ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុនត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ក.រ.ថ ឬ អ.ក។ ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ៨.៧.១ នៃ PPA ឬសំណើសុំទូទាត់ណាមួយ ពីក្រុមហ៊ុន ទៅ ក.រ.ថ ត្រូវបានទទួលដោយ អ.ក ឬ ក.រ.ថ ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថា ការទូទាត់ដោយ ក.រ.ថ ឬ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានាត្រូវធ្វើការទូទាត់ក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ។ ការយឺតយ៉ាវក្នុងការទូទាត់របស់អ្នកធានា ក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ)។ ពុំមានសំណើណាមួយ ដែលធ្វើឡើងដោយក្រុមហ៊ុន ស្របតាមលិខិតធានានេះ ដែលប៉ះពាល់ ឬដកហូតសិទ្ធិរបស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយបត្រ ដែលមិនទាន់ទូទាត់ផ្សេងទៀត។

ទឹកប្រាក់ទាំងអស់ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានកំណត់ ជាប្រាក់ដុល្លារអាមេរិកឱ្យក្រុមហ៊ុន។

៤. រាល់សំណើសុំការទូទាត់ ដែលបានធ្វើឡើងតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន នៅការិយាល័យរបស់អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត បញ្ជាក់ថា÷

"យើងខ្ញុំ សូមបញ្ជាក់ថា÷

(១). .... (ក្រុមហ៊ុន) ធ្វើសំណើសុំទូទាត់ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់ .... {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី...... ខែ....... ឆ្នាំ....... រវាង អ្នកធានា និង ក្រុមហ៊ុន។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់កាលកំណត់ និងត្រូវទូទាត់ដោយ អ.ក ឬ ក.រ.ថ ស្របតាម PPA/IA រវាងក្រុមហ៊ុន និង អ.ក ឬក.រ.ថ និងពុំមានផ្នែកណាមួយ នៃចំនួនទឹកប្រាក់ ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាង អ.ក ឬក.រ.ថ និងក្រុមហ៊ុននោះទេ។

(៣). សំណើសុំទូទាត់ពី ក.រ.ថ ឬអ.ក ជាលាយលក្ខណ៍អក្សរ បានផ្ញើរួចហើយ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ ក.រ.ថ ឬអ.ក រហូតដល់ថ្ងៃនេះ។"

៥. អ្នកធានាសូមអះអាង និងធានា នៅថ្ងៃនេះថា÷

- អ្នកធានាមានសិទ្ធិពេញសមត្ថភាព និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេតអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ។
- លិខិតធានានេះ ជាកាតព្វកិច្ចរបស់អ្នកធានា ស្របច្បាប់ មានសុពលភាព ប្រសិទ្ធភាព និងជាចំណងផ្លូវច្បាប់ អនុលោមតាមអាណត្តិរបស់លិខិតធានានេះ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រមដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ។
- កាតព្វកិច្ច និងការព្រមព្រៀងនានារបស់អ្នកធានាក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដែលក្នុងការអនុវត្តកាតព្វកិច្ចទាំងនេះ ជំនឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានាត្រូវបានប្រកាន់ខ្ជាប់។
- អ្នកធានាបានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខា ការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ។
- ប្រសិនបើមានបណ្តឹងណាមួយចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ពុំមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទសាងសង់ (Construction Commencement Date) រហូតដល់ចប់អាណត្តិ នៃ IA ឬ PPA និងត្រូវបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ណាមួយ ដែល អ.ក នៅជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនេះ ឬនៅពុំទាន់ទូទាត់។

៧. គ្មានការខកខាន ឬការយឺតយ៉ាវណាមួយ ដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយក្រោមលិខិតធានានេះ ត្រូវបានចាត់ទុកជាការបោះបង់សិទ្ធិ ឬការដោះស្រាយនោះឡើយ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក រារាំងការអនុវត្តបន្ថែមនូវសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ។ ការបដិសេធរបស់ក្រុមហ៊ុន មានប្រសិទ្ធភាព លុះត្រាតែការបដិសេធនោះធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលត្រូវបានផ្តល់ដោយច្បាប់ឡើយ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្តល់ ឬធ្វើឡើងស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវដាក់អាសយដ្ឋានបញ្ជូនទៅបុគ្គល ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមអ្នករត់សំបុត្រ។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថា បានប្រគល់÷

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ). នៅពេលប្រគល់ ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួល ដោយអ្នកផ្ញើឯកសារដែលមានការទទួលស្គាល់ជាអន្តរជាតិ បញ្ជូនទៅភាគីទទួល នៅអាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹងឱ្យទៅភាគីប្រគល់លិខិត នៅអាសយដ្ឋាន ឬលេខទូរសារ ចែងខាងក្រោម)÷

សម្រាប់ អ្នកធានា÷

ជូនចំពោះ	÷	ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អាសយដ្ឋាន	÷	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវលេខ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរសារលេខ	÷	+៨៥៥ ២៣ ៤២៧ ៧៩៨

សម្រាប់ ក្រុមហ៊ុន÷

ជូនចំពោះ	÷	ប្រធានក្រុមហ៊ុន អេសភីអេចភី (ខេមបូឌា) ឯ.ក
អាសយដ្ឋាន	÷	លេខ ៩, ផ្លូវ LyLy, សង្កាត់និរោធ, ខណ្ឌច្បារអំពៅ, ភ្នំពេញ, កម្ពុជា
ទូរសារលេខ	÷	+៨៥៥ ២៣ ៤២៦ ៤១៥

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. អ្នកធានាមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីអ្នកធានាឡើយ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់

គោលបំណងអភិវឌ្ឍន៍ ឬការផ្តល់ហិរញ្ញប្បទានអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតធានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់។ លិខិតធានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាពជាប្រយោជន៍ដល់អ្នកធានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់ របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកធានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតធានានេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយតាមច្បាប់នៃប្រទេសអង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រងមជ្ឈត្តកិច្ចផងដែរ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតធានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយ បានទទួលសេចក្តី ជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកធានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបាន តាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវបញ្ជូនវិវាទនោះ ទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើ រវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព។ សេចក្តីសម្រេច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរជាសេចក្តីសន្និដ្ឋាន និងជាចំណងផ្លូវច្បាប់ទៅលើអ្នកធានា និងក្រុមហ៊ុន និងអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការធ្វើឱ្យសេចក្តីសម្រេចនោះ អនុវត្តបាន។ ភាគីទាំងពីរត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌនូវសិទ្ធិណាមួយ ដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាពនៃសេចក្តីសម្រេចនោះ ឬយុត្តាធិការ នៃតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតធានានេះ មានប្រសិទ្ធភាពអនុវត្ត។ រាល់ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាប្រាក់ដុល្លារអាមេរិក។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ។ ភាគីដែលទទួលខុសត្រូវទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣% (បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច។

១២. ពាក្យសរសេរជាអក្សរធំដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី PPA។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើន ក្នុងលិខិតធានានេះ ត្រូវបានរកឃើញថា គ្មានសុពលភាព ខុសច្បាប់ ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិទាំងនោះ ត្រូវរក្សាតម្លៃដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ឬភាពគ្មានតម្លៃតាមផ្លូវច្បាប់នោះ ពុំមានឥទ្ធិពលដល់សុពលភាព នៃ

បញ្ញត្តិផ្សេងទៀត នៃលិខិតធានានេះឡើយ។ តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់កាត់កង ការប្តឹងទាមទារទៅវិញទៅមក ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែលអ្នកធានាមាន ឬ អាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកធានា សម្រាប់តតាំងជាមួយក្រុមហ៊ុន ទាក់ទងនឹង កាតព្វកិច្ចណាមួយរបស់អ្នកធានាចំពោះក្រុមហ៊ុន ក្រោមលិខិតធានានេះឡើយ។

១៤. លិខិតធានានេះ ត្រូវផុតសុពលភាពនៅពេលបញ្ចប់ IA និង PPA ប្រសិនបើគ្មានការទាមទារ ហើយនៅរក្សាការធានានេះដដែល ករណីមានសំណើសុំជាលាយលក្ខណ៍អក្សរណាមួយ ពីក្រុមហ៊ុនជូនមកអ្នកធានា ស្របតាមលិខិតធានានេះ ដែលត្រូវតែទទួលបានដោយអ្នកធានា មុនពេលនោះ។

១៥. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត បន្ទាប់ពីទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោកប្រធាន ទទួលនូវការរាប់អាន ពីខ្ញុំ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងរ៉ែ និងថាមពល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

№ 001 MEF/...............

Phnom Penh, 3rd May 2019

GOVERNMENT GUARANTEE OF PAYMENTS

MR. MYUNG IL KIM,
SPHP (CAMBODIA) CO., LTD.
Address: #9, St. LyLy, Sangkat Niroth,
Chbar Ampov, Phnom Penh, Cambodia
Fax No.: +855 23 999 133

Dear Sir,

We refer to:

(A) Delegation of Full Power No. 25 DFP dated 11 April 2019 by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia.

(B) The Implementation Agreement ("IA") dated 2 May 2019, entered between the Government of the Kingdom of Cambodia ("Government of the Kingdom of Cambodia") represented by Minister of Ministry of Mines and Energy ("MME") and SPHP (CAMBODIA) CO., LTD. (the "Company").

(C) ELECTRICITÉ DU CAMBODGE, a wholly state-owned limited liability enterprise incorporated by Royal Decree No. CHS/RD/0396/10 of the Government of the Kingdom of Cambodia dated 9 March 1996, with its principal office located at Street 19, Wat Phnom, Daun Penh District, Phnom Penh, in the Kingdom of Cambodia, including its successors and permitted assignees ("EDC") has entered into a Power Purchase Agreement ("PPA") with the Company dated 2 May 2019.

(D) The Government of the Kingdom of Cambodia agreed to provide: (i) a guarantee on power purchase in the event of non-payment by EDC; and (ii) a guarantee on the payment on the termination in accordance with the PPA and/or IA and in the event that the Company is unable to operate the Project arising from the Political Force Majeure Events.

(E) It is a requirement of the Implementation Agreement in accordance with its Section 5.3, the Minister of Economy and Finance on behalf of Royal Government of Cambodia (the "Guarantor") has agreed to enter into this Guarantee of the payment obligations of EDC/MME under the PPA and IA.

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

We hereby guarantee that:

1. The Guarantor hereby irrevocably and unconditionally guarantees and promises to pay to the Company any and every sum of money which is due and owed by MME or EDC to the Company under the IA or PPA that MME or EDC has failed to pay in accordance with the terms of the IA or PPA (the "Guarantee").

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MME or EDC under the IA or PPA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MME or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MME or EDC. After sixty (60) days from the date of the invoice(s) as specified in Section 8.7.1 of the PPA or any payment demand from the Company to MME being received by EDC or MME, the Company may notify the Guarantor in writing that payment from MME or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within thirty (30) Days. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). And no demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s).
All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate, that:

   "We hereby certify that:
   (1) -------------- [specify Company], (the "Company") is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of U. S. Dollars --------- [insert amount] in accordance with Section 1 of the Guarantee dated ---------, between the Guarantor and the Company;
   (2) The amount specified above is due and payable by EDC/MME under the PPA/IA between the Company and EDC/MME and no part of the amount specified above is the subject of a dispute between the EDC/MME and the Company;
   (3) Demand in writing for payment from MME/EDC has been made;
   (4) Such amount, on the date hereof, remains unpaid by MME/EDC. "

5. The Guarantor represents and warrants that, as of the date hereof:
   - The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.

- This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.
- All necessary action has been taken, and all approvals required have been obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.
- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.
- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes its unconditional and irrevocable direct obligation.
- Should any proceedings be brought against the Guarantor or its assets in any jurisdiction in relation to this Agreement, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Construction Commencement Date until the termination of the term of the IA or PPA and for so long thereafter as any amount owed to the Company by EDC in connection with such term is or may be outstanding.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing. The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:
   (a) when presented personally, or
   (b) upon the day of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such Party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

The address for service of Notice shall be:

For the Guarantor:

Attention	:	Minister, Ministry of Economy and Finance
Address	:	Ministry of Economy and Finance Street No. 92, Sangkat Wat Phnom Khan Daun Penh, Phnom Penh Kingdom of Cambodia
Facsimile	:	+855 23 427 798

For the Company:

Attention : Chairman, SPHP (CAMBODIA) CO., LTD.
Address : No. 9, St. LyLy, Sangkat Niroth, Khan Chbar Ampov, Phnom Penh, Cambodia
Fax No. : +855 23 999 133

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company, and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor. Notwithstanding the provision of the immediately preceding sentence, for the purpose of development or permanent financing of the Project, the Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee shall be governed by and construed according to the Laws of England, which shall also be the procedural law governing any arbitration.

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. Should such dispute can't be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Purchase Agreement.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee.

Subject to mutual agreement, no set-off, counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the Company shall be available to the Guarantor against the Company in connection with any obligation of the Guarantor to the Company under this Guarantee.

14. This Guarantee shall expire upon the termination of the IA and PPA if no claim has been made and remains outstanding hereunder and any written demand made to us by the Company hereunder must therefore be received by us before that time.

15. This Guarantee shall become in full force and effective on its ratification by legislatures of the Kingdom of Cambodia.

Yours faithfully

Dr. AUN PORNMONIROTH
Deputy Prime Minister, Minister,
Ministry of Economy and Finance

CC:
- Ministry of Royal Palace
- Secretariat of Senate
- Secretariat of National Assembly
- Council for the Development of Cambodia (CDC)
- Office of Council of Ministers
- Ministry of Foreign Affairs and International Cooperation
- Ministry of Mine and Energy
- Cabinet of Samdech Akka Moha Sena Padei Techo Hun Sen, Prime Minister of the Kingdom of Cambodia
- Electricity Authority of Cambodia (EAC)
- Electricite du Cambodge (EDC)
- File

ព្រះរាជក្រឹត្យ

នស/រកត/០៧១៩/១០៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈិន ចៀនឆី** (CHEN, CHIEN-CHIH) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៨៤ នៅទីក្រុង Taichung សាធារណរដ្ឋចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី (signature)

៣៧៧. ១៩០៧. ២០១៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៩

នរោត្តម សីហមុនី

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៧១៩/១០៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **សៀល ចុនអ៊ី** (SHIEH, JON-YIE) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៦៤ នៅខេត្ត Taiwan សាធារណរដ្ឋចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៧. ១៩០៧. ២០១៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៩

នរោត្តម សីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៧១៩/ ១០៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ហ្វូ សៀងផឹង** (FU, XIANGPENG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៣ នៅខេត្ត Henan សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស. ១៩០៧. ១០៩៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៩

នសីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៧១៩/ ១០៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោកស្រី **លីវ ថៃអ៊ី** (LIU, TAI-YU) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៥៣ នៅទីក្រុង Taipei សាធារណរដ្ឋចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣.៧. ១៧០៧. ១០៧៩

នរោត្តមសីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៩

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៧១៩/ ១០៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **អ៊ី ហុងប៉ូ** (YU, HONGBO) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៨១ នៅខេត្ត Fujian សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៩

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៧១៩/ ១០៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
	6112		សោហ៊ុយបេសកកម្មក្នុងប្រទេស	289,800,000	289,800,000	289,800,000	-	72,450,000	100.00%
		61121	សោហ៊ុយដឹកជញ្ជូន	34,300,000	34,300,000	34,300,000	-	8,575,000	100.00%
		61122	សោហ៊ុយបេសកកម្ម	35,600,000	35,600,000	35,600,000	-	8,900,000	100.00%
		61123	សោហ៊ុយស្នាក់នៅ	219,900,000	219,900,000	219,900,000	-	54,975,000	100.00%
	6113		សោហ៊ុយបេសកកម្មក្រៅប្រទេស	112,800,000	112,800,000	112,800,000	-	[illegible]	100.00%
		61131	សោហ៊ុយដឹកជញ្ជូន	44,200,000	44,200,000	44,200,000	-	11,050,000	100.00%
		61132	សោហ៊ុយបេសកកម្ម	7,900,000	7,900,000	7,900,000	-	1,975,000	100.00%
		61133	សោហ៊ុយស្នាក់នៅ	60,700,000	60,700,000	60,700,000	-	15,175,000	100.00%

	6114		សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍	7,000,000	7,000,000	7,000,000	-	1,750,000	100.00%
		61142	សោហ៊ុយទូរគមនាគមន៍	7,000,000	7,000,000	7,000,000	-	1,750,000	100.00%
	6198		សេវាកម្មផ្សេងៗទៀត	274,000,000	-	-	-	-	-
		61981	សេវាកម្មផ្សេងៗទៀត	274,000,000	-	-	-	-	-
ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ				4,000,000	-	-	-	-	-
65			ឧបត្ថម្ភធន	4,000,000	-	-	-	-	-
	6506		វិភាគទានដល់អង្គការ សមាគម សហព័ន្ធអន្តរជាតិនានា	4,000,000	-	-	-	-	-
		65068	អង្គការ សមាគម សហព័ន្ធអន្តរជាតិផ្សេងៗទៀត	4,000,000	-	-	-	-	-

បានឃើញ និងពិនិត្យត្រឹមត្រូវ

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៩

វ. ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា

អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ

អគ្គនាយករង

ម៉ិញ បានសុវណ្ណអានិច្ចាស័លា

បានឃើញ និងពិនិត្យត្រឹមត្រូវ

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែ [illegible] ឆ្នាំ ២០១៩

ជ. ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា

អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា

ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ

អមក្រសួងអប់រំ យុវជន និងកីឡា

បានឃើញ និងពិនិត្យត្រឹមត្រូវ

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩

ប្រធាននាយកដ្ឋានកិច្ចការទូទៅ

លី ឆុន្នី

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំចសំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩

រដ្ឋលេខាធិការប្រធាន

ហម សុហាក់

បានឃើញ និងឯកភាព

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩

រដ្ឋលេខាធិការ

ប្រធានក្រុមប្រឹក្សាទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

បណ្ឌិត. នួច_វិសាលសុខ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៣១៨.១៩.អកស៤.ប្រក

ប្រកាស
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅ នៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានកិច្ចការទូទៅ

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខដំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គនាយកដ្ឋានកិច្ចការទូទៅ។

ប្រការ២.-

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គនាយកដ្ឋានកិច្ចការទូទៅ
- រៀបចំតួនាទីនិងភារកិច្ចនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គនាយកដ្ឋានកិច្ចការទូទៅ និង
- ធានាគុណភាពនិងប្រសិទ្ធភាពនៃការដឹកនាំ គ្រប់គ្រង និងលទ្ធផលបំពេញការងារ។

ប្រការ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គនាយកដ្ឋានកិច្ចការទូទៅ។

ជំពូកទី២
បេសកកម្មនិងរចនាសម្ព័ន្ធ

ប្រការ៤.-

អគ្គនាយកដ្ឋានកិច្ចការទូទៅបំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពលដែលមានបេសកកម្មដឹកនាំលើការងាររដ្ឋបាលនិងព័ត៌មានវិទ្យា បុគ្គលិក គណនេយ្យនិងហិរញ្ញវត្ថុ ផែនការ ថវិកា នីតិកម្ម សហប្រតិបត្តិការនិងកិច្ចការអាស៊ាន និងសម្របសម្រួលការងាររបស់មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត។

ប្រការ៥.-

អគ្គនាយកដ្ឋានកិច្ចការទូទៅមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងនិងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលរបស់ក្រសួង នៅថ្នាក់ជាតិ និងរវាងថ្នាក់ជាតិ និងអង្គភាពថ្នាក់ក្រោមជាតិ
- រៀបចំនិងគ្រប់គ្រងបណ្តាញព័ត៌មានវិទ្យានិងគេហទំព័ររបស់ក្រសួងរ៉ែនិងថាមពល
- រៀបចំនិងគ្រប់គ្រងរាល់ការងារទាក់ទងនឹងមន្ត្រីរាជការ
- រៀបចំនិងគ្រប់គ្រងរាល់ការងារទាក់ទងថវិកា គណនេយ្យ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងរ៉ែនិងថាមពល
- គ្រប់គ្រងការកត់ត្រាចំណូលមិនមែនសារពើពន្ធរបស់ក្រសួងរ៉ែនិងថាមពល
- រៀបចំផែនការនិងបូកសរុបលទ្ធផលការងាររបស់ក្រសួងរ៉ែនិងថាមពល
- សហការពិនិត្យនិងផ្តល់យោបល់ និងការពារផលប្រយោជន៍ក្រសួងរ៉ែនិងថាមពលតាមផ្លូវច្បាប់
- សហការសម្របសម្រួលនិងគ្រប់គ្រងការងារទាក់ទងនឹងកិច្ចសហប្រតិបត្តិការនិងកិច្ចការអាស៊ានរបស់ក្រសួងរ៉ែនិងថាមពល និង
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួងរ៉ែនិងថាមពល។

ប្រការ៦.-

អគ្គនាយកដ្ឋានកិច្ចការទូទៅដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករងមួយចំនួនអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

ប្រការ៧.-

អគ្គនាយកដ្ឋានកិច្ចការទូទៅមាននាយកដ្ឋានក្រោមឱវាទចំនួន០៦(ប្រាំមួយ)ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាលនិងព័ត៌មានវិទ្យា
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
- នាយកដ្ឋានផែនការ
- នាយកដ្ឋាននីតិកម្ម និង
- នាយកដ្ឋានសហប្រតិបត្តិការនិងកិច្ចការអាស៊ាន។

ប្រការ៨.-

នាយកដ្ឋាននីមួយៗនិងការិយាល័យចំណុះឱ្យនាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

អង្គការលេខរបស់អគ្គនាយកដ្ឋានកិច្ចការទូទៅមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ជំពូកទី៣
នាយកដ្ឋានរដ្ឋបាលនិងព័ត៌មានវិទ្យា

ប្រការ៩.-

នាយកដ្ឋានរដ្ឋបាលនិងព័ត៌មានវិទ្យាបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងាររដ្ឋបាលនិងព័ត៌មានវិទ្យាដោយមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលសកម្មភាពរដ្ឋបាលរបស់ក្រសួងនៅថ្នាក់កណ្តាលនិងរវាងថ្នាក់កណ្តាលជាមួយអង្គភាពថ្នាក់ក្រោមជាតិនិងអង្គភាពដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស
- ដំណើរការច្រកចេញចូលតែមួយដើម្បីគ្រប់គ្រងការធ្វើចរាចរលិខិតនិងឯកសារនានា
- សហការរៀបចំ គ្រប់គ្រង និងដំណើរការផ្នែកបច្ចេកទេសនូវគេហទំព័រនិងបណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួងសម្រាប់ដំណើរការការងាររបស់ក្រសួង
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងចូលរួមសម្របសម្រួលរៀបចំការងារសង្គមរបស់ក្រសួង
- រៀបចំទុកដាក់ឯកសារ
- រៀបចំសម្របសម្រួលការងារពិធីការរបស់ក្រសួង
- គ្រប់គ្រងយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទរបស់ក្រសួង ព្រមទាំងធ្វើផែនការតម្រូវការប្រេងឥន្ធនៈនិងលើកគម្រោងបែងចែកការប្រើប្រាស់ប្រេងឥន្ធនៈនិងគ្រឿងបន្លាស់
- ទទួលនិងលើកគម្រោងបែងចែកសម្ភារៈបរិក្ខារជូនអង្គភាពក្រោមចំណុះក្រសួង
- រៀបចំ គ្រប់គ្រងដំណើរការ និងថែរក្សាបណ្តាញប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួង និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ប្រការ១០.-

នាយកដ្ឋានរដ្ឋបាលនិងព័ត៌មានវិទ្យាមានការិយាល័យក្រោមឱវាទចំនួន០៥(ប្រាំ)ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យព័ត៌មានវិទ្យា
- ការិយាល័យផ្គត់ផ្គង់
- ការិយាល័យពិធីការ និង
- ការិយាល័យជួសជុលនិងថែទាំ។

ប្រការ១១.-

ការិយាល័យរដ្ឋបាលជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ទទួលបន្ទុកត្រួតពិនិត្យនិងតាមដានការធ្វើចរាចរលិខិត ឯកសារគ្រប់ប្រភេទរបស់ក្រសួង
- គ្រប់គ្រងការទទួលឯកសារនិងផ្ញើឯកសារតាមរយៈសារអេឡិចត្រូនិចរបស់ក្រសួង
- បែងចែកនិងបញ្ជូនលិខិតឯកសារគ្រប់ប្រភេទរបស់ក្រសួង
- សម្របសម្រួលរាល់សកម្មភាពការងាររដ្ឋបាលរបស់នាយកដ្ឋានជាមួយនឹងអង្គភាពនានា
- ទទួលបន្ទុកធ្វើលិខិតបញ្ជាបេសកកម្មក្នុងប្រទេស លិខិតអញ្ជើញ លិខិតឧទ្ទេសនាមវិញ្ញាបនបត្ររដ្ឋបាល និងតាក់តែងលិខិតរដ្ឋបាលផ្សេងៗ
- រៀបរៀងបទបញ្ជាផ្ទៃក្នុងពាក់ព័ន្ធសុវត្ថិភាព សណ្តាប់ធ្នាប់ និងអនាម័យរបស់ក្រសួង
- ផ្តល់ព័ត៌មាននិងទិន្នន័យការងារសម្រាប់បម្រើឱ្យការងាររដ្ឋបាលរបស់ក្រសួង
- ប្រមូលរៀបចំចងក្រងនិងទុកដាក់រាល់សំណុំឯកសារដែលបានមកពីចរន្តការងាររបស់ក្រសួងនិងឯកសារដែលពាក់ព័ន្ធនឹងការងាររាជរដ្ឋាភិបាល ស្ថាប័ននានា តាមលំដាប់នៃសម័យកាលនីមួយៗ ដោយធ្វើការបែងចែកនិងបង់លេខកូដតាមប្រភេទនៃឯកសារ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងនិងស្រាវជ្រាវបម្រើការងារចំពោះមុខ
- សហការចងក្រងឯកសារជាសៀវភៅ កម្រងរូបភាព និងឯកសារភាពយន្តអំពីសកម្មភាពការងាររបស់ក្រសួង
- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន

- គ្រប់គ្រង ផ្គត់ផ្គង់ បែងចែកនិងថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ជីវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយស និងពង្រឹងវិន័យក្នុងនាយកដ្ឋាន និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យព័ត៌មានវិទ្យាជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំអភិវឌ្ឍ ថែរក្សា និងគ្រប់គ្រងផ្នែកបច្ចេកទេស គេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួង
- រៀបចំអភិវឌ្ឍនិងដំណើរការបណ្តាញកុំព្យូទ័រ អ៊ីនធឺណែត កាមេរ៉ាសុវត្ថិភាព និងប្រព័ន្ធទូរស័ព្ទផ្ទៃក្នុងរបស់ក្រសួង
- រៀបចំអភិវឌ្ឍនិងដំណើរការប្រព័ន្ធម៉ាស៊ីនមេរបស់ក្រសួង
- ផ្តល់សេវាបច្ចេកទេសព័ត៌មានវិទ្យាជូនអង្គភាពក្រោមឱវាទក្រសួងតាមសំណូមពរ
- សម្របសម្រួលនិងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យចាំបាច់ជូនអង្គភាពក្រោមឱវាទក្រសួង និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យផ្គត់ផ្គង់ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យអំពីស្ថានភាពតម្រូវការជាក់ស្តែង ហើយលើកគម្រោងផ្គត់ផ្គង់និងបែងចែកសម្ភារៈបរិក្ខារការិយាល័យ ប្រេងឥន្ធនៈ គ្រឿងសង្ហារឹម ជូនថ្នាក់ដឹកនាំ និងអង្គភាពចំណុះក្រសួង ហើយដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច
- លើកគម្រោងថវិកានិងផ្គត់ផ្គង់គ្រឿងបរិក្ខារចាំបាច់សម្រាប់ដំណើរការពិធីសន្និបាត សិក្ខាសាលានិងរាល់កិច្ចប្រជុំសំខាន់ៗរបស់ក្រសួង
- លើកគម្រោងថវិកានិងផ្គត់ផ្គង់សម្ភារៈបរិក្ខារសម្រាប់ចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិរបស់ក្រសួង
- លើកគម្រោងថវិកាសម្រាប់ចំណាយលើការប្រើប្រាស់ទឹក អគ្គិសនី និងប្រព័ន្ធទំនាក់ទំនង
- លើកសំណើរាល់ការចំណាយពាក់ព័ន្ធនឹងការផ្គត់ផ្គង់និងចំណាយផ្សេងៗ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យពិធីការជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលនិងទទួលភារកិច្ចពិធីការក្នុងកម្មវិធីផ្លូវការនិងពិធីបុណ្យជាតិនានារបស់ក្រសួង

- សហការរៀបចំនិងចូលរួមពិធីបុណ្យជាតិនិងអន្តរជាតិផ្សេងៗ និងទទួលជូនដំណើរគណៈប្រតិភូជាតិ អន្តរជាតិនានា
- រៀបចំបែបបទ លិខិតស្នាមផ្សេងៗ និងមធ្យោបាយដឹកជញ្ជូន សម្រាប់ទទួលនិងជូនដំណើរថ្នាក់ដឹកនាំក្នុងពេលបំពេញបេសកកម្ម
- សម្របសម្រួលកម្មវិធីទស្សនកិច្ចជូនថ្នាក់ដឹកនាំក្រសួងនិងភ្ញៀវអន្តរជាតិ
- សម្របសម្រួលអញ្ជើញអ្នកសារព័ត៌មានជាតិអន្តរជាតិដើម្បីចូលរួមកម្មវិធីរបស់ក្រសួង
- គ្រប់គ្រង ការពារសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការតុបតែងលម្អ ដើម្បីធានាសោភ័ណ្ឌភាពរបស់ក្រសួង
- គ្រប់គ្រង រៀបចំសាលប្រជុំរួមរបស់ក្រសួងជូនថ្នាក់ដឹកនាំនិងអង្គភាពចំណុះក្រសួង និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យជួសជុលនិងថែទាំជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- លើកគម្រោង គ្រប់គ្រង និងតាមដានការងារសាងសង់ ជួសជុល សម្ភារៈបរិក្ខារ និងអគាររបស់ក្រសួង
- រៀបចំគម្រោងចំណាយ និងលើកសំណើថវិកាពាក់ព័ន្ធនឹងការសាងសង់ ជួសជុល និងថែទាំ
- គ្រប់គ្រងនិងថែរក្សាចលនទ្រព្យ និងអចលនទ្រព្យរបស់ក្រសួង
- សហការរៀបចំបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋរបស់ក្រសួងនិងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំតាមកាលកំណត់ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៤
នាយកដ្ឋានបុគ្គលិក

ប្រការ១២.-

នាយកដ្ឋានបុគ្គលិកបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារបុគ្គលិកដោយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងគ្រប់គ្រងផ្នែករដ្ឋបាលមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈមិនមែនមន្ត្រីរាជការរបស់ក្រសួង
- រៀបចំលិខិតបទដ្ឋាននិងលិខិតរដ្ឋបាលសម្រាប់គ្រប់គ្រងអាជីព
- គ្រប់គ្រងសំណុំលិខិតជីវប្រវត្តិមន្ត្រីរាជការស្ថិតក្នុងក្របខណ្ឌមុខងារសាធារណៈ
- រៀបចំធនធានមនុស្សរបស់ក្រសួងទៅតាមជំនាញឯកទេស
- លើកគម្រោងវាយតម្លៃតម្រូវការតែងតាំង ដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការផ្លាស់ប្តូរប្រភេទក្របខណ្ឌ ផ្ទេរប្តូរ និងសម្រួលភារកិច្ចមន្ត្រីរាជការ
- លើកគម្រោងវាយតម្លៃនិងលើកសំណើដើម្បីផ្តល់បណ្ណសរសើរនិងគ្រឿងឥស្សរិយយសផ្សេងៗជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងនិងជំនាញការបរទេសប្រចាំក្រសួងដែលមានស្នាដៃល្អ

- រៀបចំស្ថិតិមន្ត្រីរាជការនិងតារាងព័ត៌មានប្រតិបត្តិ
- រៀបចំការងារបៀវត្សពលកម្ម ប្រាក់កម្រៃ និងរបបឧបត្ថម្ភសន្តិសុខសង្គម
- រៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាលដោយធ្វើការវាយតម្លៃលើតម្រូវការនិងលើកគម្រោងបណ្តុះបណ្តាលមន្ត្រីរាជការរយៈពេលខ្លី មធ្យម និងវែងតាមតម្រូវការជាក់ស្តែងរបស់ក្រសួង និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ប្រការ១៣.-

នាយកដ្ឋានបុគ្គលិកមានការិយាល័យក្រោមឱវាទចំនួន០៦(ប្រាំមួយ)ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យមន្ត្រីរាជការ
- ការិយាល័យបណ្តុះបណ្តាល
- ការិយាល័យបៀវត្សនិងសន្តិសុខសង្គម និង
- ការិយាល័យវិភាគមុខងារ។

ប្រការ១៤.-

ការិយាល័យរដ្ឋបាលជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង ផ្គត់ផ្គង់ បែងចែកនិងថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ជីវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយសនិងពង្រឹងវិន័យក្នុងនាយកដ្ឋាន និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យមន្ត្រីរាជការជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោមៈ

- ចងក្រង គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពស្ថិតិមន្ត្រីរាជការក្រោមឱវាទក្រសួង
- រៀបចំគម្រោងថវិកានិងដំណើរការកម្មវិធីប្រឡងប្រជែងជ្រើសរើសក្របខណ្ឌមន្ត្រីថ្មី
- លើកគម្រោងវាយតម្លៃនិងធ្វើសំណើសម្រាប់ការតែងតាំង ការប្រគល់ភារកិច្ចការផ្ទេរនិងការសម្រួលភារកិច្ចជំនួសអគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និងប្រធានមន្ទីររាជធានី ខេត្ត ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេចតាមការចាំបាច់របស់ក្រសួង
- ពិនិត្យនិងវាយតម្លៃលើសំណើសុំតែងតាំងប្រធានមន្ទីររាជធានីខេត្តដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច
- ពិនិត្យនិងវាយតម្លៃលើដីកាតែងតាំងអនុប្រធានមន្ទីរ ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានការិយាល័យជំនាញប្រចាំក្រុង ស្រុក ខណ្ឌ នៅតាមរាជធានី ខេត្ត ដើម្បីជូនថ្នាក់ដឹកនាំជ្រាបនិងផ្ដល់មតិណែនាំបន្ថែមក្នុងករណីចាំបាច់
- ពិនិត្យនិងរៀបចំការស្នើសុំតាំងស៊ប់ក្នុងក្របខណ្ឌ
- តាមដាននិងបូកសរុបលទ្ធផលការអនុវត្តវិន័យគ្រប់អង្គភាពចំណុះក្រសួងរួចធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំជាប្រចាំ
- លើកសំណើវិធានការវិន័យជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេចចំពោះមន្ត្រីដែលមិនបានអនុវត្តតាមគោលការណ៍វិន័យដែលមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា
- ចងក្រងរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីលើកជាគោលការណ៍របស់ក្រសួងសម្រាប់ណែនាំដល់អង្គភាពចំណុះក្រសួងអំពីការគ្រប់គ្រងមន្ត្រីរាជការដោយអនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនិងការណែនាំផ្សេងៗរបស់ក្រសួងមុខងារសាធារណៈ
- លើកគម្រោង ពិនិត្យ និងរៀបចំធ្វើបណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការក្រសួង
- លើកគម្រោងវាយតម្លៃនិងលើកសំណើដើម្បីផ្ដល់បណ្ណសរសើរនិងគ្រឿងឥស្សរិយយសផ្សេងៗជូនដល់ថ្នាក់ដឹកនាំមន្ត្រីរាជការក្រសួងនិងជំនាញការបរទេសប្រចាំក្រសួងដែលមានស្នាដៃល្អ
- តាក់តែងលិខិតស្នាមពាក់ព័ន្ធនឹងការងារជំនាញ
- រៀបចំតម្កល់និងថែរក្សាសំណុំលិខិតឯកសារពាក់ព័ន្ធនឹងការងារជំនាញ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យបណ្ដុះបណ្ដាលជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោមៈ

- រៀបចំគម្រោងផែនការបណ្ដុះបណ្ដាលរយៈពេលខ្លី មធ្យម និងវែងជូនមន្ត្រីរាជការក្រសួងតាមតម្រូវការជាក់ស្ដែងជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច
- ធ្វើទំនាក់ទំនងនិងផ្សព្វផ្សាយអំពីវគ្គបណ្ដុះបណ្ដាលនិងអាហារូបករណ៍ជូនដល់មន្ត្រីរាជការក្រសួង

- ពិនិត្យនិងផ្តល់យោបល់លើបេក្ខភាពមន្ត្រីរាជការដែលត្រូវទទួលការបណ្តុះបណ្តាលតាមគោលការណ៍របស់ក្រសួងមុខងារសាធារណៈនិងតាមតម្រូវការជាក់ស្តែងរបស់ក្រសួង
- សម្របសម្រួលនិងចាត់បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលនៅក្នុងនិងក្រៅប្រទេស
- ត្រួតពិនិត្យនិងវាយតម្លៃពីប្រសិទ្ធភាពនិងប្រសិទ្ធផលរបស់មន្ត្រីដែលបានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាផ្សេងៗនិងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំជាប្រចាំ
- ធ្វើទំនាក់ទំនងតាមបណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពចំណុះក្រសួង ដើម្បីទទួលយករបាយការណ៍ប្រចាំត្រីមាស ឆមាសនិងប្រចាំឆ្នាំ ស្តីពីការចាត់បញ្ជូនមន្ត្រីរាជការឱ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សារយៈពេលវែងខ្លី តាមការអញ្ជើញរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ឬអង្គការជាតិអន្តរជាតិនានា
- តាក់តែងលិខិតផ្សេងៗពាក់ព័ន្ធនឹងការជ្រើសរើសមន្ត្រីរាជការឱ្យចូលរួមវគ្គបណ្តុះបណ្តាល
- តាក់តែងលិខិតស្នាមនិងថែរក្សាសំណុំលិខិតឯកសារពាក់ព័ន្ធនឹងការងារជំនាញ
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំអំពីលទ្ធផលការងារដែលអនុវត្តបាន និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យបៀវត្សនិងសន្តិសុខសង្គម ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សិក្សាលើគម្រោងផែនការឥណទានបៀវត្ស និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈនិងផ្នែកធានារ៉ាប់រងសង្គមប្រចាំខែ និងប្រចាំឆ្នាំ
- រៀបចំបៀវត្ស ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល ស្ថានភាពគ្រួសារ ប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការ និវត្តជន បាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំឈប់ពីការងារ និងលំហែមាតុភាព
- រៀបចំគោលការណ៍ណែនាំដល់គ្រប់អង្គភាពចំណុះក្រសួងអំពីបែបបទនិងលក្ខខណ្ឌ នៃការស្នើសុំរៀបចំបៀវត្សថ្មី ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការលុបឈ្មោះ ការចូលនិវត្តន៍ការចូលបាត់បង់សម្បទាវិជ្ជាជីវៈ លំហែមាតុភាព មរណភាព ស្របតាមលិខិតបទដ្ឋានគតិយុត្តនិងតាមការណែនាំរបស់ក្រសួងមុខងារសាធារណៈ
- ពិនិត្យ និងរៀបចំ ក្នុងការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ផ្លាស់ប្តូរក្របខណ្ឌ លុបឈ្មោះ ការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ការស្ថិតនៅក្រៅក្របខណ្ឌ ការចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព លំហែមាតុភាពរបស់មន្ត្រីរាជការក្រសួង
- តាក់តែងរាល់លិខិតឆ្លើយឆ្លងរបស់ក្រសួងលើការងារជំនាញ
- គ្រប់គ្រងថែរក្សាសំណុំលិខិត ឯកសារពាក់ព័ន្ធនឹងការងារជំនាញ
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារដែលអនុវត្តបានជូនថ្នាក់ដឹកនាំ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យវិភាគមុខងារជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សិក្សា តាមដាន និងវិភាគមុខងារ ដើម្បីស្នើសុំបង្កើត កែសម្រួល ឬរំសាយអង្គភាពចំណុះក្រសួងតាមការចាំបាច់
- សិក្សាលើកគម្រោងផែនការក្របខណ្ឌនិងធ្វើការបែងចែកក្របខណ្ឌជូនអង្គភាពចំណុះក្រសួង
- សហការរៀបចំបង្កើតគណៈកម្មាធិការ គណៈកម្មការ ក្រុមការងារ ក្រុមជំនួយការ ផ្សេងៗ តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង
- វិភាគមុខងារ តាមដាន ត្រួតពិនិត្យ និងជំរុញការបែងចែកតួនាទីភារកិច្ចជូនមន្ត្រីតាមអង្គភាពចំណុះក្រសួងនិងរៀបចំរបាយការណ៍បូកសរុបជូនថ្នាក់ដឹកនាំ
- តាក់តែងលិខិតស្នាមនិងថែរក្សាសំណុំលិខិតឯកសារដែលពាក់ព័ន្ធនឹងការងារជំនាញ
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំអំពីលទ្ធផលការងារដែលអនុវត្តបាន និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៥
នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ

ប្រការ១៥.-

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារគណនេយ្យនិងហិរញ្ញវត្ថុដោយមានភារកិច្ចដូចខាងក្រោម៖

- លើកគម្រោងកម្មវិធីនៃការអនុវត្តចំណូលចំណាយថវិកាក្រសួងប្រចាំត្រីមាស
- គ្រប់គ្រងការអនុវត្តមាតិកាថវិកាប្រចាំឆ្នាំរបស់ក្រសួងស្របតាមច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ
- រៀបចំ គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានៃសកម្មភាពខាងហិរញ្ញវត្ថុនិងបន្ទុកគណនី
- ផ្ទៀងផ្ទាត់និងបូកសរុបការអនុវត្តថវិកាប្រចាំឆ្នាំរបស់ក្រសួង
- តាមដានការគ្រប់គ្រងគណនីពិសេស
- ពិនិត្យនិងសម្របសម្រួលដោះស្រាយរាល់ការចំណាយរបស់ក្រសួង
- តាមដាន កត់ត្រា និងបូកសរុបការប្រមូលចំណូលប្រចាំឆ្នាំរបស់ក្រសួង
- ចងក្រងធ្វើបច្ចុប្បន្នភាពនិងផ្ទៀងផ្ទាត់បញ្ជីចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌផ្សេងៗ
- សម្របសម្រួលនិងលើកស្នើធ្វើការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួង និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ប្រការ១៦.-

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុមានការិយាល័យក្រោមឱវាទចំនួន០៥(ប្រាំ)ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យគ្រប់គ្រងចំណាយ
- ការិយាល័យគ្រប់គ្រងចំណូល
- ការិយាល័យគណនេយ្យ និង
- ការិយាល័យទ្រព្យសម្បត្តិរដ្ឋ។

ប្រការ១៧.-

ការិយាល័យរដ្ឋបាលជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង ផ្គត់ផ្គង់ បែងចែក និងថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ជីវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយស និងពង្រឹងវិន័យក្នុងនាយកដ្ឋាន និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យគ្រប់គ្រងចំណាយជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ធ្វើការបូកសរុបគម្រោងកម្មវិធីការអនុវត្តចំណាយថវិកាក្រសួងប្រចាំត្រីមាស
- ពិនិត្យនិងផ្តល់មតិនូវរាល់សំណើចំណាយ
- រៀបចំដំណើរការឯកសារដើម្បីដោះស្រាយនិងទូទាត់ចំណាយថវិកាតាមនីតិវិធីហិរញ្ញវត្ថុ
- រៀបចំដំណើរការឯកសារនិងទូទាត់បន្ទុកបុគ្គលិក
- គ្រប់គ្រងបញ្ជីសលាកប័ត្រនិងការងារអាណត្តិកិច្ច
- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានូវរាល់ប្រតិបត្តិការចំណាយ

- បូកសរុបរបាយការណ៍ចំណាយប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំរបស់ក្រសួង
- រៀបចំផ្ទួផ្ទងរបាយការណ៍ចំណាយជាមួយនឹងអង្គភាពពាក់ព័ន្ធ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យគ្រប់គ្រងចំណូលជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- បូកសរុបគម្រោងកម្មវិធីការអនុវត្តចំណូលថវិកាក្រសួងប្រចាំត្រីមាស
- តាមដាន កត់ត្រានិងបូកសរុបការប្រមូលចំណូលប្រចាំឆ្នាំរបស់ក្រសួង
- តាមដាននិងបូកសរុបតួលេខ ប្រាក់ជំពាក់ ប្រាក់បំណុល ប្រាក់វិវាទ និងលើកសំណើដោះស្រាយជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច
- រៀបចំផ្ទួផ្ទងរបាយការណ៍ចំណូលជាមួយអង្គភាពពាក់ព័ន្ធ
- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានូវរាល់ប្រតិបត្តិការចំណូល
- រៀបចំរបាយការណ៍ចំណូលប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យគណនេយ្យជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយនិងណែនាំស្ដីពីការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងគណនេយ្យ
- ត្រួតពិនិត្យនិងបូកសរុបរបាយការណ៍ចំណូលចំណាយរបស់ក្រសួង
- តាមដាននិងរៀបចំរបាយការណ៍សមតុល្យគណនីរបស់ក្រសួងប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាសនិងប្រចាំឆ្នាំ
- ប្រមូលនិងរក្សាសក្ខីបត្រពាក់ព័ន្ធប្រតិបត្តិការចំណូលចំណាយរបស់ក្រសួង
- ពិនិត្យ រៀបចំ និងតាមដានឯកសារស្នើសុំនិយ័ត ផ្ទេរ និងបន្ថែមឥណទាន
- រៀបចំ ផ្ទួផ្ទងរបាយការណ៍សម្រេចទូទាត់ចំណូលចំណាយជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដានរបាយការណ៍ក្នុងប្រព័ន្ធព័ត៌មានវិទ្យានូវរាល់ប្រតិបត្តិការចំណូលចំណាយ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យទ្រព្យសម្បត្តិរដ្ឋជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយនិងណែនាំក្នុងការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារទ្រព្យសម្បត្តិរដ្ឋ
- ពិនិត្យនិងលើកសំណើទាក់ទងអំពីការជួល លក់ ឬផ្ទេរអចលនទ្រព្យ
- ចងក្រងធ្វើបច្ចុប្បន្នភាពនិងផ្ទៀងផ្ទាត់បញ្ជីចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌផ្សេងៗ និង

- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៦
នាយកដ្ឋានផែនការ

ប្រការ១៨.-

នាយកដ្ឋានផែនការបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារផែនការ គម្រោងថវិកា និងបូកសរុបដោយមានភារកិច្ចដូចខាងក្រោម៖

- សហការ សម្របសម្រួល និងផ្ដល់ធាតុចូលជូនស្ថាប័ននិងអង្គភាពពាក់ព័ន្ធក្នុងការងាររៀបចំចងក្រងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍជាតិនានា
- សហការនិងសម្របសម្រួលជាមួយនឹងអង្គភាពពាក់ព័ន្ធក្នុងការងាររៀបចំគោលនយោបាយ ផែនការសកម្មភាព និងធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍពាក់ព័ន្ធនឹងវិស័យរបស់ក្រសួង
- តាមដានការអនុវត្តតាមផែនការសកម្មភាពនិងផែនការអភិវឌ្ឍរបស់ក្រសួង
- សហការ រៀបចំ ចងក្រង គ្រប់គ្រង ធ្វើបច្ចុប្បន្នភាព បោះពុម្ព និងផ្សព្វផ្សាយ ស្ថិតិពាក់ព័ន្ធនឹងវិស័យរបស់ក្រសួង
- បូកសរុបនិងធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំស្ដីពីសកម្មភាព និងលទ្ធផលការងាររបស់ក្រសួង
- រៀបចំចងក្រងឯកសារជាសៀវភៅ កម្រងរូបភាព និងឯកសារភាពយន្ត អំពីសកម្មភាព និងលទ្ធផលការងាររបស់ក្រសួង
- រៀបចំ សម្របសម្រួល និងបូកសរុបគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់ក្រសួង
- សហការនិងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធដើម្បីរៀបចំសំណើវិភាជថវិកា តាមមាតិកាកម្មវិធីនិងមាតិកាសេដ្ឋកិច្ចជូនគ្រប់អង្គភាពថវិកាចំណុះក្រសួង
- ជំរុញ តាមដាន និងវាយតម្លៃតាមមាតិកាកម្មវិធីស្ដីពីការអនុវត្តផែនការថវិការបស់គ្រប់អង្គភាពថវិកាចំណុះក្រសួង និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ប្រការ១៩.-

នាយកដ្ឋានផែនការមានការិយាល័យក្រោមឱវាទចំនួន០៤(បួន)ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យគោលនយោបាយនិងផែនការ
- ការិយាល័យស្ថិតិនិងបូកសរុប និង
- ការិយាល័យគម្រោងផែនការថវិកា។

ប្រការ២០.-

ការិយាល័យរដ្ឋបាលជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន

- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង ផ្គត់ផ្គង់ និងលើកសំណើបែងចែកទ្រព្យសម្បត្តិនិងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរសក្តិ គ្រឿងឥស្សរិយយស និងពង្រឹងវិន័យក្នុងនាយកដ្ឋាន និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យគោលនយោបាយនិងផែនការ ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សហការនិងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីផ្តល់ធាតុចូលពីបច្ចុប្បន្នភាពពាក់ព័ន្ធ វិស័យរបស់ក្រសួងក្នុងការងាររៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍជាតិនានា
- សហការនិងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍនានារបស់ក្រសួង
- សហការនិងតាមដានការអនុវត្តតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍនានារបស់ក្រសួង
- ផ្សព្វផ្សាយគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍជាតិនានា ជូនអង្គភាពចំណុះក្រសួងដើម្បីជ្រាបជាព័ត៌មាន
- សហការផ្សព្វផ្សាយគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍនានារបស់ក្រសួង និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យស្ថិតិនិងបូកសរុបជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំសំណើរបបនិងទម្រង់របាយការណ៍ ធ្វើបច្ចុប្បន្នភាពរបបនិងទម្រង់របាយការណ៍ក្នុងករណីចាំបាច់និងជំរុញអង្គភាពចំណុះក្រសួងឱ្យប្រើប្រាស់ទម្រង់របាយការណ៍ដែលបានរៀបចំ ដើម្បីធ្វើការបូកសរុបសកម្មភាពនិងលទ្ធផលការងាររបស់អង្គភាព

- សរុបរាល់សកម្មភាព ទិន្នន័យ និងលទ្ធផលការងាររបស់ក្រសួងដើម្បីរៀបរៀងជាអត្ថបទរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំសម្រាប់ផ្ញើជូនរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ
- សហការរៀបរៀង ចងក្រង ធ្វើបច្ចុប្បន្នភាព និងគ្រប់គ្រងទិន្នន័យនិងស្ថិតិពាក់ព័ន្ធវិស័យរបស់ក្រសួង
- សហការ បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យនិងស្ថិតិពាក់ព័ន្ធនឹងវិស័យរបស់ក្រសួង
- រៀបចំចងក្រងឯកសារជាសៀវភៅ កម្រងរូបភាព និងឯកសារភាពយន្ត អំពីសកម្មភាពនិងលទ្ធផលការងាររបស់ក្រសួង
- សហការផ្សព្វផ្សាយសកម្មភាពនិងលទ្ធផលការងាររបស់ក្រសួង និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យគម្រោងផែនការថវិកាជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សហការនិងរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ដោយធ្វើការចងក្រងនិងបូកសរុបគម្រោងចំណូល ចំណាយប្រចាំឆ្នាំ និងបីឆ្នាំរំកិលរបស់ក្រសួង
- សហការ រៀបចំនិងចងក្រងឯកសារចាំបាច់នានា និងធ្វើការវេចខ្ចប់គម្រោងថវិការបស់ក្រសួង ដើម្បីត្រៀមឆ្លងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សហការនិងសម្របសម្រួលការងារឆ្លងគម្រោងថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសម្រេចបានផែនការថវិការបស់ក្រសួង
- សហការនិងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធដើម្បីរៀបចំសំណើវិភាជថវិកា តាមមាតិកាកម្មវិធីនិងមាតិកាសេដ្ឋកិច្ចជូនគ្រប់អង្គភាពថវិកាចំណុះក្រសួង
- ជំរុញ តាមដាន និងវាយតំលៃការអនុវត្តផែនការថវិកាតាមមាតិកាកម្មវិធី
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាតាមមាតិកាកម្មវិធីរបស់គ្រប់អង្គភាពថវិកា
- សហការផ្សព្វផ្សាយអំពីលទ្ធផលនៃការអនុវត្តថវិកាតាមមាតិកាកម្មវិធីរបស់គ្រប់អង្គភាពថវិកា និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៧
នាយកដ្ឋាននីតិកម្ម

ប្រការ២១.-

នាយកដ្ឋាននីតិកម្មបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារនីតិកម្ម ដោយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋានជំនាញនូវរាល់ការរៀបចំនិងតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាតបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនីក្នុងក្រសួងព្រមទាំងជាមួយនឹងស្ថាប័នពាក់ព័ន្ធ

- ជាទីប្រឹក្សាច្បាប់ដល់ថ្នាក់ដឹកនាំក្រសួង
- ទទួលបន្ទុកត្រួតពិនិត្យលើទម្រង់និងគតិច្បាប់នូវរាល់លិខិតបទដ្ឋានគតិយុត្តនានាដែលអគ្គនាយកដ្ឋានជំនាញបានរៀបចំនិងតាក់តែងមុននឹងដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច
- សម្របសម្រួលនិងរៀបចំកិច្ចប្រជុំក្រុមការងារ កិច្ចប្រជុំអន្តរក្រសួង ក្នុងដំណើរការនៃការឆ្លងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា
- ផ្តល់យោបល់លើការអនុវត្តវិធានការច្បាប់នូវរាល់ភាពមិនអនុលោមនិងបទល្មើសផ្សេងៗក្នុងវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី
- ការពារតាមផ្លូវច្បាប់នូវសេចក្តីសម្រេច សកម្មភាព និងការអនុវត្តរបស់ក្រសួងនិងសម្របសម្រួលដំណើរការដោះស្រាយវិវាទផ្សេងៗរវាងក្រសួងជាមួយភាគីពាក់ព័ន្ធ
- ធ្វើការសិក្សាវាយតម្លៃនិងតាមដានលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់និងសិក្ខាសាលាផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា
- ស្រាវជ្រាវ វិភាគ ចងក្រង ធ្វើបច្ចុប្បន្នភាព និងតម្កល់ឯកសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាតិអន្តរជាតិក្នុងវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី
- ទទួលបន្ទុកជាលេខាធិការដ្ឋាននៃក្រុមការងារពង្រឹងយន្តការដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ប្រការ២២.-

នាយកដ្ឋាននីតិកម្មមានការិយាល័យក្រោមឱវាទចំនួន០៤(បួន)ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យច្បាប់
- ការិយាល័យសម្រុះសម្រួលនិងដោះស្រាយវិវាទ និង
- ការិយាល័យស្រាវជ្រាវនិងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។

ប្រការ២៣.-

ការិយាល័យរដ្ឋបាលជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារ និងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន

- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំ របស់នាយកដ្ឋាន
- គ្រប់គ្រង ផ្គត់ផ្គង់ បែងចែក និងថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ជីវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយសនិងពង្រឹងវិន័យក្នុងនាយកដ្ឋាន និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យច្បាប់ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមសហការរៀបចំពិនិត្យផ្តល់មតិជាមួយបណ្តាអគ្គនាយកដ្ឋានជំនាញលើការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី
- ចូលរួមចរចានិងតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា កិច្ចសន្យា និងកិច្ចព្រមព្រៀងនានាពាក់ព័ន្ធនឹងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី
- ធ្វើជាជំនួយការផ្នែកច្បាប់ក្នុងវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី សម្រាប់ថ្នាក់ដឹកនាំនិងអង្គភាពបច្ចេកទេសក្រោមអាណាព្យាបាលរបស់ក្រសួង
- ស្រាវជ្រាវ ដកស្រង់ វិភាគនិងចងក្រងលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិនានាក្នុងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី
- រៀបចំគម្រោងនិងដំណើរការសិក្ខាសាលាផ្សព្វផ្សាយការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី
- ធ្វើបច្ចុប្បន្នភាពកម្រងលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិនានា និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យសម្រុះសម្រួលនិងដោះស្រាយវិវាទជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- លើកសំណើពីយន្តការនៃការសម្រុះសម្រួលវិវាទទៅតាមករណីជាក់ស្តែងនីមួយៗជូនថ្នាក់ដឹកនាំ

- ផ្តល់មតិយោបល់លើនីតិវិធីក្នុងការដាក់ពាក្យបណ្តឹងនិងនីតិវិធីជំនុំជម្រះរបស់តុលាការគ្រប់ជាន់ថ្នាក់ជូនថ្នាក់ដឹកនាំ
- ផ្តល់ការប្រឹក្សាយោបល់ផ្នែកច្បាប់ពាក់ព័ន្ធនឹងវិវាទរវាងក្រសួងជាមួយភាគីពាក់ព័ន្ធនិងធ្វើជាអន្តរការីដើម្បីសហការជាមួយមេធាវីការពារក្រសួងនៅចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់
- សហការជាមួយអង្គភាពនិងស្ថាប័នពាក់ព័ន្ធ ដោយរាយការណ៍និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំព្រមទាំងស្នើសុំអនុសាសន៍ណែនាំដើម្បីរៀបចំដាក់ពាក្យបណ្តឹងទៅតុលាការចំពោះបទល្មើសក្នុងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី
- ស្រាវជ្រាវ វិភាគ ដកស្រង់ និងចងក្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការសម្រុះសម្រួលនិងដោះស្រាយវិវាទក្នុងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យស្រាវជ្រាវនិងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ចងក្រងគោលការណ៍ណែនាំផ្សេងៗស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- ធ្វើការវិភាគជាបឋមនិងពេញលេញលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តផ្សេងៗក្នុងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី
- សហការជាមួយបណ្តាអគ្គនាយកដ្ឋានជំនាញដែលបាននឹងកំពុងរៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗសម្រាប់វិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនីដើម្បីអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- ធ្វើរបាយការណ៍នៃការវាយតម្លៃលើសំណើតាក់តែងលិខិតបទដ្ឋានគតិយុត្តនិងបទ-ប្បញ្ញត្តិនានា ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច
- ស្រាវជ្រាវ វិភាគ ចងក្រងនិងបោះពុម្ពផ្សាយអត្ថបទ កម្រងឯកសារគតិយុត្តផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី
- សម្របសម្រួលកិច្ចដំណើរការនៃក្រុមការងារពង្រឹងយន្តការដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៨
នាយកដ្ឋានសហប្រតិបត្តិការនិងកិច្ចការអាស៊ាន

ប្រការ២៤.-

នាយកដ្ឋានសហប្រតិបត្តិការនិងកិច្ចការអាស៊ានស្ថិតនៅក្រោមការគ្រប់គ្រងនិងដឹកនាំផ្ទាល់ដោយអគ្គនាយកដ្ឋានកិច្ចការទូទៅ ដែលមានភារកិច្ចពាក់ព័ន្ធការងារសហប្រតិបត្តិការលើវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនីដូចខាងក្រោម៖

- ចូលរួមសិក្សាវិភាគនិងតស៊ូមតិក្នុងក្របខណ្ឌសហប្រតិបត្តិការតំបន់និងអន្តរតំបន់ដើម្បីការពារផលប្រយោជន៍ជាតិ
- សហការនិងសម្របសម្រួលជាមួយអគ្គនាយកដ្ឋានជំនាញនិងស្ថាប័នពាក់ព័ន្ធក្នុងការជំរុញរៀបចំលើកគម្រោងសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងអន្តរជាតិ និងជំរុញអនុវត្តន៍រាល់គំនិតផ្តួចផ្តើមនិងគម្រោងកម្មវិធីតំបន់ អន្តរតំបន់
- តាមដាន បូកសរុប និងផ្សព្វផ្សាយពីលទ្ធផលនៃការអនុវត្តគម្រោងកម្មវិធីតំបន់ អន្តរតំបន់
- រៀបចំបដិសណ្ឋារកិច្ច សំណុំលិខិតឯកសារផ្សេងៗ និងគ្រប់គ្រងគម្រោងចំណាយ សម្រាប់កិច្ចដំណើរការសហប្រតិបត្តិការ
- ចូលរួមក្នុងសកម្មភាពសហប្រតិបត្តិការលើវិស័យជំនាញផ្សេងៗ
- ចងក្រង គ្រប់គ្រង និងថែរក្សារាល់ឯកសារសហប្រតិបត្តិការផ្សេងៗ
- ដើរតួជាលេខាធិការដ្ឋានជូនថ្នាក់ដឹកនាំទទួលបន្ទុកអ្នកនាំពាក្យក្រសួង
- សហការរៀបចំនិងធ្វើបច្ចុប្បន្នភាពនូវអត្ថបទសកម្មភាពការងាររបស់ក្រសួងដើម្បីផ្សព្វផ្សាយក្នុងគេហទំព័របណ្ដាញទំនាក់ទំនងសង្គមនិងការងារទំនាក់ទំនងសាធារណៈ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ប្រការ២៥.-

នាយកដ្ឋានសហប្រតិបត្តិការនិងកិច្ចការអាស៊ានមានការិយាល័យក្រោមឱវាទចំនួន០៤(បួន)ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យសហប្រតិបត្តិការ
- ការិយាល័យព័ត៌មាននិងប្រតិកម្មរហ័ស និង
- ការិយាល័យទំនាក់ទំនងសាធារណៈ។

ប្រការ២៦.-

ការិយាល័យរដ្ឋបាលជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន

- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង ផ្គត់ផ្គង់ បែងចែក និងថែរក្សាទ្រព្យសម្បត្តិនិងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ជីវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយសនិងពង្រឹងវិន័យក្នុងនាយកដ្ឋាន និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យសហប្រតិបត្តិការជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សហការជាមួយអគ្គនាយកដ្ឋានជំនាញក្នុងក្រសួង និងបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធនឹងលេខាធិការដ្ឋានអន្តរជាតិនានា ដើម្បីជំរុញអនុវត្តគម្រោងសហប្រតិបត្តិការរបស់ក្រសួង
- សហការជាមួយអគ្គនាយកដ្ឋានជំនាញក្នុងក្រសួងនិងបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចូលរួមប្រជុំគស៊ូមតិក្នុងក្របខណ្ឌសហប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យក្រសួងក្នុងការការពារផលប្រយោជន៍ជាតិ
- សិក្សាស្រាវជ្រាវគំរូសហប្រតិបត្តិការអន្តរជាតិ ចងក្រងសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងគម្រោងអភិវឌ្ឍន៍នានា និងឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងការងារសហប្រតិបត្តិការ ដើម្បី ផ្តល់ធាតុចូល រៀបចំយុទ្ធសាស្ត្រ និងផែនការសហប្រតិបត្តិការ
- ចូលរួមតាក់តែងនិងផ្តល់ប្រឹក្សាយោបល់លើអនុស្សារណៈនៃការយោគយល់គ្នា ពិធីសារ និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការផ្សេងៗ
- ដើរតួនាទីជាលេខាធិការដ្ឋានសម្របសម្រួល និងចូលរួមធ្វើកំណត់ហេតុ សម្រាប់ដំណើរការកិច្ចប្រជុំអន្តរជាតិ និងកិច្ចសហប្រតិបត្តិការនានា
- បូកសរុប តាមដាន វាយតម្លៃ និងធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិ កំណត់ហេតុកិច្ចប្រជុំនិងគម្រោងសហប្រតិបត្តិការផ្សេងៗ

- លើកគម្រោងផែនការសកម្មភាព និងគម្រោងចំណាយដើម្បីអនុវត្តផែនការសហប្រតិបត្តិការប្រចាំឆ្នាំរបស់ក្រសួង
- លើកគម្រោងចំណាយលើការរៀបចំកិច្ចប្រជុំថ្នាក់អន្តរជាតិនានារបស់ក្រសួង
- ចងក្រង រៀបចំទុកដាក់ឯកសារសហប្រតិបត្តិការរបស់ក្រសួង
- សហការជាមួយនាយកដ្ឋានបុគ្គលិកក្នុងការស្វែងរកជំនួយពីដៃគូអភិវឌ្ឍដើម្បីអនុវត្តផែនការ បណ្តុះបណ្តាលធនធានមនុស្ស និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន

ការិយាល័យព័ត៌មាននិងប្រតិកម្មរហ័សជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- តាមដានការវិវឌ្ឍនៃសភាពការណ៍នយោបាយ សង្គម និងសេដ្ឋកិច្ចពាក់ព័ន្ធវិស័យរបស់ក្រសួងដើម្បីជាមូលដ្ឋានក្នុងការរៀបចំយុទ្ធសាស្ត្រឆ្លើយតបជូនក្រសួង
- តាមដាន ពិនិត្យ ជ្រើសរើស និងចងក្រងព័ត៌មានសាធារណៈដែលពាក់ព័ន្ធនឹងវិស័យរបស់ក្រសួងជាប្រចាំ
- រៀបចំសេចក្តីបំភ្លឺរបស់ក្រសួងជូនអ្នកនាំពាក្យក្រសួងដើម្បីធ្វើការឆ្លើយបំភ្លឺទាន់ពេលវេលា
- សហការរៀបចំសន្និសីទសារព័ត៌មានជូនក្រសួង
- គ្រប់គ្រងនិងធ្វើបច្ចុប្បន្នភាពគេហទំព័រនិងបណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួង
- សហការរៀបចំ ចងក្រង និងតាក់តែងអត្ថបទពាក់ព័ន្ធសកម្មភាពការងាររបស់ក្រសួងដើម្បីផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គម
- ទទួលបន្ទុកដំណើរការប្រព័ន្ធទំនាក់ទំនងយន្តការបណ្តឹងតវ៉ាផ្លូវការរបស់ក្រសួង និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ការិយាល័យទំនាក់ទំនងសាធារណៈជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលរៀបចំបង្កើត គាំទ្រ និងដំណើរការកម្មវិធីបង្កើនការយល់ដឹងអំពីគោលនយោបាយ ចក្ខុវិស័យ ផែនការសកម្មភាព និងបេសកកម្មរបស់ក្រសួងជូនសាធារណជន
- បំពេញតួនាទីជាអ្នកសម្របសម្រួលផ្តល់ព័ត៌មាននិងផ្សព្វផ្សាយនូវផែនការ គម្រោង និងឱកាសវិនិយោគដល់វិនិយោគិនជាតិ និងអន្តរជាតិ
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការប្រមូល ចងក្រង ភាពយន្តឯកសារ និងកម្រងរូបភាពផ្សេងៗអំពីសមិទ្ធផលនិងសកម្មភាពការងារដែលបានអនុវត្តដើម្បីផ្សព្វផ្សាយ
- លើកគម្រោងចំណាយសម្រាប់ការងារទំនាក់ទំនងសាធារណៈប្រចាំឆ្នាំ និង
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៩
អវសានប្បញ្ញត្តិ

ប្រការ២៧.-

ប្រកាសលេខ១៨៤ រថ.អកទទ.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានកិច្ចការទូទៅនិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ២៨.-

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយក ប្រធាននាយកដ្ឋាន ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសៅរ៍ ៣កើតខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០១៨
រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស៊ុយ_សែម

កន្លែងទទួល :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ២៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ០៣១៨.១៩.សសស.ប្រក ចុះថ្ងៃទី២៥ ខែ ឆ្នាំ២០១៩

អង្គការលេខរបស់អគ្គនាយកដ្ឋានកិច្ចការទូទៅ



សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី